**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ២៨ សាលខ**

# សារលិខិត

## សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសប្រារព្ធទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២២

- សូមក្រាបថ្វាយបង្គំសម្ដេចព្រះអគ្គមហាសង្ឃរាជទាំងពីរគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីគោរពសក្ការៈ!
- សម្ដេច ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី!
- បងប្អូន កូនក្មួយ ចៅៗ ជនរួមជាតិទាំងអស់ជាទីស្រឡាញ់!

ក្នុងឱកាសដ៏មហោឡារិកនៃការប្រារព្ធទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២២នេះ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំ ក្នុងនាមរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសម្ដែងនូវមនោសញ្ចេតនារីករាយ និងគាំទ្រយ៉ាងពេញទំហឹងចំពោះការរៀបចំទិវាដ៏មានសារៈសំខាន់នេះជាមួយបណ្ដាប្រទេសនានា និងការិយាល័យអង្គការសហប្រជាជាតិសម្រាប់គ្រួតពិនិត្យគ្រឿងញៀននិងបទឧក្រិដ្ឋ ដែលជារៀងរាល់ឆ្នាំតែងតែបានដាក់ចេញនូវប្រធានបទផ្សេងៗ អាស្រ័យតាមស្ថានភាព បរិបទ និងភាពចំបាច់សម្រាប់ឆ្នាំនីមួយៗ។ សម្រាប់ឆ្នាំ២០២២នេះ ដោយយល់ឃើញពីផលប៉ះពាល់និងបញ្ហានានាដែលពិភពលោកយើងទាំងមូលបាន និងកំពុងប្រឈមយ៉ាងធ្ងន់ធ្ងរលើគ្រប់វិស័យ ពិសេសសេដ្ឋកិច្ច សង្គមកិច្ច សុខុមាលភាព សង្គម និងមនុស្សធម៌ ដែលបាននឹងកំពុងបង្កឡើងដោយជំងឺឆ្លងរាតត្បាតកូវីដ-១៩ និងសង្គ្រាមនៅប្រទេសអ៊ុយក្រែននោះ ការិយាល័យអង្គការសហប្រជាជាតិសម្រាប់គ្រួតពិនិត្យគ្រឿងញៀននិងបទឧក្រិដ្ឋ (UNODC) បានដាក់ចេញប្រធានបទ "ដោះស្រាយបញ្ហាគ្រឿងញៀនក្នុងវិបត្តិសុខភាពនិងមនុស្សធម៌" (Addressing drug challenges in health and humanitarian crises) ដើម្បីជំរុញនូវការលើកកម្ពស់ប្រសិទ្ធភាពនៃការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅក្នុងកាលៈទេសៈដែលពិភពលោកបាននិងកំពុងជួបប្រទះទៅនឹងបញ្ហាប្រឈមជាច្រើន ជាពិសេសក្នុងបរិបទនៃវិបត្តិសុខភាពនិងមនុស្សធម៌។

និងផ្តន្ទាទោសទៅតាមច្បាប់។ ជាក់ស្តែងយើងបានប្រកាសបើកដាក់ឱ្យដំណើរការនូវមជ្ឈមណ្ឌលជាតិព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនដោយស្ម័គ្រចិត្តនៅខេត្តព្រះសីហនុដោយទទួលយកយុវជនរងគ្រោះដោយគ្រឿងញៀនឱ្យចូលទៅស្នាក់នៅសម្រាកព្យាបាលនិងស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ ចំណេះជំនាញស្របតាមទីផ្សារការងារ និងបានបន្តពង្រឹងប្រសិទ្ធភាពការផ្តល់សេវាព្យាបាល និងស្តារនីតិសម្បទា នៅតាមមជ្ឈមណ្ឌលបណ្តោះអាសន្ន មណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែកនៅតាមមូលដ្ឋានជូនបងប្អូន កូនក្មួយ ចៅៗដែលជាជនរងគ្រោះដោយសារគ្រឿងញៀនជាធម្មតា។ រាជរដ្ឋាភិបាល ក៏បានបន្តដាក់ចេញនិងអនុវត្តនូវយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៧ នៅទូទាំងប្រទេសយ៉ាងមានប្រសិទ្ធភាព ដោយបានបង្ក្រាបបទល្មើសគ្រឿងញៀនធំៗជាច្រើនករណីចាប់យកវត្ថុតាងជាគ្រឿងញៀនបានជាច្រើនរយគីឡូក្រាម និងសារធាតុគីមីផ្សំគ្រឿងញៀន ជាច្រើនតោនរួមជាមួយវត្ថុតាងផ្សេងៗជាច្រើនទៀត។

សមិទ្ធផលទាំងនេះ គឺជាការខិតខំប្រឹងប្រែងប្រកបដោយការយកចិត្តទុកដាក់ខ្ពស់របស់សមត្ថកិច្ចនិងមន្ត្រីបម្រើការងារក្នុងវិស័យប្រយុទ្ធប្រឆាំងគ្រឿងញៀន រួមជាមួយវិស័យឯកជន សាសនា អង្គការមនុស្សធម៌ជាតិ អន្តរជាតិ វិស័យឯកជន និងអ្នកពាក់ព័ន្ធដទៃទៀតរបស់យើង ដែលជាសក្ខីភាពបង្ហាញពីការប្តេជ្ញាយ៉ាងមុតមាំរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនជាសេនាធិការ ក្នុងការដោះស្រាយបញ្ហាគ្រឿងញៀន ដោយប្រកាន់យកនូវតុល្យភាពរវាងបញ្ហាសុខភាព មនុស្សធម៌ និងវិធានការច្បាប់ព្រមទាំងចាត់ទុកអ្នកប្រើគ្រឿងញៀនគឺជាជនរងគ្រោះដែលត្រូវទទួលបានការយកចិត្តទុកដាក់ព្យាបាល ស្តារនីតិសម្បទា ជាជាងទទួលនូវការចោទប្រកាន់តាមផ្លូវច្បាប់ ស្របតាមប្រធានបទប្រចាំឆ្នាំរបស់អង្គការ **យូ អិន អូ ឌី ស៊ី** ដោយឈរលើគោលការណ៍សុខភាពនិងមនុស្សធម៌ជាមូលដ្ឋាន បើទោះបីស្ថិតក្នុងកាលៈទេសៈលំបាកនិងប្រឈមយ៉ាងណាក្តី។

- សម្តេចព្រះអគ្គមហាសង្ឃរាជទាំងពីរគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីគោរពសក្ការៈ!
- បងប្អូនជនរួមជាតិទាំងអស់ជាទីស្នេហា!

ទោះបីយើងខិតខំប្រឹងប្រែងទទួលបានលទ្ធផលដូចខាងលើនេះក្តី ប៉ុន្តែដោយនិន្នាការរួមជាសកល កម្ពុជាយើង ក៏ដូចជាបណ្តាប្រទេសដទៃទៀត នៅតែប្រឈមគួរឱ្យព្រួយបារម្ភពីការប៉ុនប៉ងផលិត កែច្នៃ រក្សាទុក ជួញដូរ និងប្រើប្រាស់គ្រឿងញៀនទាំងក្នុងពេលបច្ចុប្បន្ននិងទៅអនាគត។ យោងលើស្ថានភាពនេះ និងក្នុងគោលដៅរក្សាបាននូវនិរន្តរភាពនៃប្រសិទ្ធភាពការងារជាបន្តទៀតនោះ ពិសេសក្នុងបរិបទពិភពលោកទាំងមូលបាននិងកំពុងប្រឈមទៅនឹងវិបត្តិនានា ពិសេសផ្នែកសុខភាពនិងមនុស្សធម៌នោះ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំសូមធ្វើការណែនាំនិងសំណូមពរ បន្ថែមទៅលើបទបញ្ជា គោលការណ៍ណែនាំ ដែលបានដាក់ចេញកន្លងមកមួយចំនួនទៀត ដូចតទៅ៖

១- សូមអំពាវនាវដល់បងប្អូនកូនក្មួយ ព្រមទាំងចៅៗជាជនរួមជាតិទាំងអស់ ពិសេសមាតាបិតា និងអាណាព្យាបាល សូមបន្តចូលរួម និងគាំទ្រឱ្យបានកាន់តែសកម្មថែមទៀត ដើម្បីរួមគ្នាបង្ការ ទប់ស្កាត់ និងដោះស្រាយនូវរាល់បញ្ហាដែលអាចកើតមាននៅក្នុងសហគមន៍។

ក្នុងនាមសមាជិកនៃអនុសញ្ញា និងពិធីសារស្តីពីគ្រឿងញៀនរបស់អង្គការសហប្រជាជាតិ ព្រះរាជាណាចក្រកម្ពុជាបានយកចិត្តទុកដាក់អនុវត្តន៍និងបំពេញកាតព្វកិច្ចយ៉ាងសកម្មប្រកបដោយការទទួលខុសត្រូវខ្ពស់ទាំងក្នុងកម្រិតជាតិ អនុតំបន់ តំបន់ និងអន្តរជាតិក្នុងគ្រប់កាលៈទេសៈ។ ជាក់ស្តែងក្នុងឆ្នាំ២០២២នេះ បើទោះបីជាប្រទេសកម្ពុជា ក៏ដូចជាពិភពលោកទាំងមូលបាននិងកំពុងបន្តទទួលរងនូវបញ្ហាប្រឈមជាច្រើន ដែលបង្កឡើងដោយជំងឺកូវីដ-១៩ និងបញ្ហាសង្គ្រាមនៅប្រទេសអ៊ុយក្រែនក្តី ក៏រាជរដ្ឋាភិបាលកម្ពុជា នៅតែបន្តផ្តោតការយកចិត្តទុកដាក់ ដោយចាត់ទុកការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅតែជាការងារអាទិភាពមួយក្នុងចំណោមការងារអាទិភាពនានារបស់រាជរដ្ឋាភិបាល។

**ជនរួមជាតិទាំងអស់ជាទីស្នេហា!**

ជំងឺឆ្លងរាតត្បាតកូវីដ-១៩ ដែលបាននិងកំពុងកើតមានឡើង រួមជាមួយនឹងការផ្ទុះឡើងនៃសង្គ្រាមនៅប្រទេសអ៊ុយក្រែនក្នុងរយៈពេលជិត៤ខែកន្លងមកនេះ បាននិងកំពុងធ្វើឱ្យពិភពលោក និងមនុស្សជាតិយើងទាំងមូលទទួលរងនូវផលប៉ះពាល់ទាំងដោយផ្ទាល់ និងដោយប្រយោលយ៉ាងធ្ងន់ធ្ងរបំផុត។ ក្នុងនោះប្រក្រតីភាពនៃដំណើរការសេដ្ឋកិច្ច វប្បធម៌ សង្គមធម៌ និងជីវភាពសង្គម ក៏ដូចជាសុខភាពសតិអារម្មណ៍ ផ្លូវកាយ ផ្លូវចិត្តរបស់បុគ្គល ត្រូវបានធ្លាក់ចុះ ប្រែប្រួល និងកែប្រែទម្លាប់គួរឱ្យកត់សម្គាល់។ ជាមួយនេះការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ក៏ដូចជាការដោះស្រាយនូវបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងគ្រឿងញៀន ក៏បាននិងកំពុងប្រឈមជាមួយនឹងការលំបាកជាច្រើន ដូចវិស័យផ្សេងៗផងដែរ។ ក្នុងន័យនេះ ប្រធានបទរបស់អង្គការ **យូ អិន អូ ឌី ស៊ី (UNODC)** ក្នុងឆ្នាំនេះ គឺមានគោលបំណងអំពាវនាវលើកទឹកចិត្តនិងជំរុញដល់បណ្តារដ្ឋជាសមាជិកទាំងអស់ ឱ្យបន្តផ្តោតការយកចិត្តទុកដាក់បន្ថែមទៀត ក្នុងការដោះស្រាយបញ្ហាគ្រឿងញៀនឱ្យកាន់តែមានប្រសិទ្ធភាព ដោយផ្អែកលើគោលការណ៍សុខភាព និងមនុស្សធម៌ជាមូលដ្ឋានចម្បង។

ជាការពិតមកដល់ពេលនេះ រាជរដ្ឋាភិបាលកម្ពុជាពិតជាទទួលបានជោគជ័យនិងមានមោទនភាពក្រៃលែងដែលបានបង្ការ ទប់ស្កាត់ គ្រប់គ្រង និងជួយសង្គ្រោះជីវិតប្រជាជនកម្ពុជាបានស្ទើរតែទាំងស្រុងពីគ្រោះមហន្តរាយដល់អាយុជីវិតនៃការឆ្លងរាតត្បាតជំងឺកូវីដ-១៩ ក្រោមគោលនយោបាយចាក់ស្រោចវ៉ាក់សាំងដល់ប្រជាជនកម្ពុជា ១០០% និងបន្តចាក់ដូសជំរុញជាបន្តបន្ទាប់រហូតមកនេះ។ ភាពជោគជ័យនេះ មិនត្រឹមតែអាចជួយសង្គ្រោះជីវិតប្រជាជនយើងពីការស្លាប់ប៉ុណ្ណោះទេ តែក៏ជាការផ្តល់ឱកាសដ៏មានតម្លៃដល់រាជរដ្ឋាភិបាល ក៏ដូចជាប្រជាជនគ្រប់រូបក្នុងការវិលត្រឡប់មករកប្រក្រតីភាពនៃជីវភាពសង្គម សេដ្ឋកិច្ច និងបើកដំណើរការប្រទេសតាមគន្លងប្រក្រតីភាពថ្មីឡើងវិញ ក្នុងនោះរួមទាំងការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ទាំងលើផ្នែកព្យាបាល ស្តារនីតិសម្បទា ការងារផ្សព្វផ្សាយ អប់រំ និងការងារអនុវត្តច្បាប់ដោយបានចាត់វិធានការតាមគ្រប់មធ្យោបាយនិងលទ្ធភាព ដើម្បីធ្វើការទប់ស្កាត់និងបង្ក្រាបបានទាន់ពេលវេលានូវរាល់ការប៉ុនប៉ង ផលិត កែច្នៃ រក្សាទុក ជួញដូរ និងចរាចរគ្រឿងញៀនខុសច្បាប់ទាំងមកពីខាងក្រៅនិងនៅផ្ទៃក្នុងប្រទេស ហើយក្រុមឧក្រិដ្ឋជននិងជនល្មើសជាច្រើននាក់ដោយរួមទាំងមេក្លោងធំៗ និងបណ្តាញជួញដូរគ្រឿងញៀនទាំងក្នុងស្រុក និងឆ្លងដែនមួយចំនួនត្រូវបានចាប់ខ្លួន

ជាមួយនេះ ខ្ញុំក៏សូមឱ្យមាតាបិតានិងអាណាព្យាបាល បន្តយកចិត្តទុកដាក់ថែទាំ និងអប់រំកូនចៅឱ្យបានល្អ ដើម្បីឱ្យពួកគេលូតលាស់ធំធាត់ប្រកបដោយសុខភាពនិងសុវត្ថិភាព បៀសផុតពីបញ្ហាគ្រឿងញៀន បញ្ហាអវិជ្ជមានក្នុងសង្គមផ្សេងៗទៀត ដើម្បីអនាគតកូនចៅយើង។

២- គ្រប់ក្រសួង ស្ថាប័ន វិស័យឯកជន និងសាសនា ត្រូវបន្តលើកកម្ពស់ការអនុវត្តសកម្មភាពផ្សព្វផ្សាយអប់រំពីផលប៉ះពាល់នៃគ្រឿងញៀនឱ្យបានផុលផុស និងគ្រប់គោលដៅប្រយោម។ ជាពិសេស បណ្តាញផ្សព្វផ្សាយព័ត៌មាន សិល្បករ សិល្បការិនី បណ្តាញទំនាក់ទំនងសង្គម និងហ្វេសប៊ុកផេករបស់ថ្នាក់ដឹកនាំ ដោយត្រូវបន្តអនុវត្តផ្សារភ្ជាប់ជាមួយខ្លឹមសារទិសស្លោក បីកុំ មួយរាយការណ៍ គឺៈកុំពាក់ព័ន្ធ កុំអន្តរាគមន៍ កុំលើកលែង និងត្រូវរាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ចគ្រប់ករណីគ្រឿងញៀន។

៣- អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត ពិសេសក្រសួងសុខាភិបាល និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវបន្តពង្រឹងគុណភាពប្រសិទ្ធភាព និងភាពជឿជាក់នៃការផ្តល់សេវាព្យាបាល ស្តារនីតិ សម្បទាទាំងនៅក្នុងមជ្ឈមណ្ឌលជាតិ មជ្ឈមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋនិងឯកជន និងមន្ទីរពេទ្យបង្អែក មណ្ឌលសុខភាពនានា ព្រមទាំងសម្របសម្រួលគាំទ្រ លើកទឹកចិត្ត និងជំរុញឱ្យអ្នកប្រើគ្រឿងញៀនឱ្យទៅទទួលយកសេវាព្យាបាលស្តារនីតិសម្បទា ក្នុងមូលដ្ឋានរបស់ខ្លួន។

៤- អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន គណៈកម្មការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៧ គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត និងអង្គភាព ពាក់ព័ន្ធទាំងអស់ត្រូវបន្តយកចិត្តទុកដាក់ម្ចាស់ការ សម្របសម្រួល ដឹកនាំអនុវត្តឱ្យកាន់តែមានប្រសិទ្ធភាពនូវតួនាទី និងភារកិច្ចរបស់ខ្លួនក្នុងការបង្ការ ទប់ស្កាត់ បង្ក្រាប និងដោះស្រាយនូវរាល់បញ្ហាដែលមានការពាក់ព័ន្ធនឹងគ្រឿងញៀន និងគ្រប់គ្រង ត្រួតពិនិត្យសារធាតុគីមីផ្សំ នៅតាមក្រុមហ៊ុន រោងចក្រ សហគ្រាសឱ្យបានហ្មត់ចត់និងមានប្រសិទ្ធភាពខ្ពស់ ដើម្បីទប់ស្កាត់បានរាល់ការលួចបង្វែរពីជំនួញស្របច្បាប់យកទៅកែច្នៃផលិតគ្រឿងញៀនខុសច្បាប់នៅក្នុងប្រទេសកម្ពុជា។

៥- គ្រប់ក្រសួង ស្ថាប័ន អង្គភាពមន្ត្រីអនុវត្តច្បាប់គ្រឿងញៀនពាក់ព័ន្ធទាំងអស់ ត្រូវបន្តលើកកម្ពស់ការប្រើប្រាស់យន្តការនៃកិច្ចសហប្រតិបត្តិការអន្តរជាតិ ទាំងក្របខ័ណ្ឌទ្វេភាគី ពហុភាគី ទាំងក្នុងតំបន់ និងសកលលោក ផ្លាស់ប្តូរព័ត៌មានត្រួតពិនិត្យ តាមដានស៊ើបអង្កេត ស្រាវជ្រាវមុខសញ្ញាចរាចរ ជួញដូរ ប្រើប្រាស់គ្រឿងញៀន និងសារធាតុគីមីផ្សំខុសច្បាប់ឆ្លងកាត់តំបន់ព្រំដែន និងសហការរួមគ្នាបង្ក្រាបឱ្យបានទាន់ពេលវេលា និងចំគោលដៅ។

ជាថ្មីម្ដងទៀត ខ្ញុំសូមអំពាវនាវដល់គ្រប់ក្រសួង ស្ថាប័ន អាជ្ញាធរមានសមត្ថកិច្ច កម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ វិស័យសាសនា វិស័យឯកជន អង្គការជាតិ អន្តរជាតិ និងបងប្អូន កូនក្មួយ ចៅៗជាជនរួមជាតិទាំងអស់ ពិសេសមាតាបិតានិងអាណាព្យាបាល សូមបន្តចូលរួមនិងគាំទ្រឱ្យបានកាន់តែសកម្មថែមទៀត ក្នុងយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី៧ របស់រាជរដ្ឋាភិបាលកម្ពុជា និងរួមគ្នាបន្តទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩ តាមរយៈការអនុវត្តវិធានការសុខាភិបាល និងបន្តចាក់វ៉ាក់សាំងប្រឆាំងជំងឺកូវីដ-១៩ដូសជំរុញឱ្យបានគ្រប់ៗគ្នា ។

មុននឹងបញ្ចប់ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំសូមថ្លែងអំណរព្រះគុណចំពោះសម្ដេចព្រះអគ្គមហាសង្ឃរាជទាំងពីរគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងសូមអរគុណចំពោះថ្នាក់ដឹកនាំ និងមន្ត្រីគ្រប់លំដាប់ថ្នាក់នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត វិស័យសាសនា វិស័យឯកជន សប្បុរសជន សិល្បករ សិល្បការិនី ពិធីករ ពិធីការិនី ម្ចាស់ជំនួយ អង្គការមិនមែនរដ្ឋាភិបាលជាតិ-អន្តរជាតិ និងអ្នកពាក់ព័ន្ធទាំងអស់ដែលបានផ្ដល់នូវការគាំទ្រយ៉ាងពេញទំហឹង និងចូលរួមយ៉ាងសកម្មផុលផុស ធ្វើឱ្យការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនក្លាយទៅជាចលនាជាតិដ៏សំខាន់មួយក្នុងការលើកកម្ពស់សុខុមាលភាពសង្គម រួមចំណែកដល់ការពង្រឹងសន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ និងការអភិវឌ្ឍប្រទេសជាតិស្របតាមគោលនយោបាយ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល។

ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា សម្ដេចព្រះអគ្គមហាសង្ឃរាជទាំងពីរគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ សម្ដេច ឯកឧត្ដម លោកជំទាវ លោក លោកស្រី បងប្អូនកូនក្មួយ ជាជនរួមជាតិទាំងអស់ ពិសេសស្ថានីយវិទ្យុ ទូរទស្សន៍ និងប្រព័ន្ធផ្សព្វផ្សាយសង្គមផ្សេងៗទៀតនឹងចូលរួមអនុវត្តប្រកបដោយការទទួលខុសត្រូវខ្ពស់ និងផ្សព្វផ្សាយឱ្យបានទូលំទូលាយ ដើម្បីបានជាឧត្ដមប្រយោជន៍រួមរបស់ប្រជាជននិងប្រទេសជាតិនៃយើង។

ជាទីបញ្ចប់ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំ សូមថ្វាយព្រះពរ និងប្រគេនពរ សម្ដេចព្រះអគ្គមហាសង្ឃរាជទាំងពីរគណៈ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាគោរពទីសក្ការៈ និងសូមជូនពរដល់ជនរួមជាតិទាំងអស់ សូមប្រកបដោយពុទ្ធពរទាំងបួនប្រការ **អាយុ វណ្ណៈ សុខៈ** និង**ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃសុក្រ ១០រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២២ ✓

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**